# ព្រះរាជក្រម

នស/រកម/០២១៦/០០៥

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

រដ្ឋសភា
ចូល
លេខ ៥៥៦
ថ្ងៃទី០១/០៣ ឆ្នាំ២០១៦ ម៉ោង១៥:៣០
បញ្ជូនទៅ ៥.១

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

# ច្បាប់

## ស្តីពី

## ការទូទាត់ថវិកាទូទៅរបស់រដ្ឋ
## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ
## ផ្នែកទី ១
## កិច្ចប្រតិបត្តិការទូទៅ

**មាត្រា ១._**

ត្រូវបានយល់ព្រមលើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ។ ការអនុវត្តនេះ សម្រេចបានលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោម :

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ | ឆ្នាំ២០១៤ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូល = (I.១ + II.១) | ១៣ ៦៦៥ ៦២៧,០ | ១៥ ២៧០ ៩៤០,៨ | ១១១,៧% | +១ ៦០៥ ៣១៣,៨ |
| សរុបចំណាយ = (I.២ + II.២) | ១៣ ៥៩៥ ៦២៧,០ | ១៤ ០៦៧ ៩៣២,០ | ១០៣,៥% | +៤៧២ ៣០៥,០ |
| អតិរេកថវិការវាងចំណូលនិងចំណាយ | +៧០ ០០០,០ | +១ ២០៣ ០០៨,៨ | | |
| I. កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាថ្នាក់ជាតិ ដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិ | | | | |
| I.១.ចំណូលថវិកា | ១០ ២០៥ ៦២៧,០ | ១១ ០៣០ ៤៦០,៩ | ១០៨,១% | +៨២៤ ៨៣៣,៩ |
| • ចំណូលចរន្ត | ៩ ៧១២ ៦២៧,០ | ១០ ៨២៩ ៦៩៦,៦ | ១១១,៥% | +១ ១១៧ ០៦៩,៦ |
| • ចំណូលមូលធនក្នុងប្រទេស | ២៣៣ ០០០,០ | ១៨៣ ៩៩៦,១ | ៧៩,០% | -៤៩ ០០៣,៩ |
| • ចំណូលមូលនិធិទ្រទ្រង់ថវិកា | ២៦០ ០០០,០ | ១៦ ៧៦៨,២ | ៦,៤% | -២៤៣ ២៣១,៨ |
| I.២.ចំណាយថវិកា | ១០ ១៣៥ ៦២៧,០ | ៩ ៨២៧ ៤៥២,១ | ៩៧,០% | -៣០៨ ១៧៤,៩ |
| • ចំណាយចរន្ត | ៨ ២៦៨ ៧០៣,០ | ៨ ២០៤ ៤៤១,៧ | ៩៩,២% | -៦៤ ២៦១,៣ |
| • ចំណាយមូលធន | ១ ៨៦៦ ៩២៤,០ | ១ ៦២៣ ០១០,៤ | ៨៦,៩% | -២៤៣ ៩១៣,៦ |
| II.វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | | | |
| II.១.ចំណូលមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៤៦០ ០០០,០ | ៤ ២៤០ ៤៧៩,៩ | ១២២,៦% | +៧៨០ ៤៧៩,៩ |
| II.២.ចំណាយមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៤៦០ ០០០,០ | ៤ ២៤០ ៤៧៩,៩ | ១២២,៦% | +៧៨០ ៤៧៩,៩ |

**មាត្រា ២.-**

ចំណូលថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងចំណុច I នៃតារាង "**ក**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ត្រូវបានបង្ហាញលម្អិតតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកនៅក្នុងតារាង "**ខ**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

លទ្ធផលដែលសម្រេចបានពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តមិនឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤: ចំពោះចំណូលត្រូវបានបង្ហាញនៅក្នុងចំណុច II នៃតារាង "**ក**" និងចំពោះចំណាយត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ខ២**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

## ផ្នែកទី ២
## កិច្ចប្រតិបត្តិការចំណូល-ចំណាយអនុវត្តឆ្លងកាត់រតនាគារជាតិ

**មាត្រា ៣.-**

ការប្រមូលចំណូលជាគុណប្រយោជន៍នៃថវិកាថ្នាក់ជាតិពីពន្ធ អាករ វិភាគទាន ផលទុន និងចំណូលនានា ព្រមទាំងឧបត្ថម្ភធនវិនិយោគ អំណោយ មូលនិធិបដិភាគ និងធនធាន ដែលបានមកពីការខ្ចី ដូចមានចែងក្នុងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ សម្រេចបានលទ្ធផលដូចតទៅ :

- ច្បាប់ហិរញ្ញវត្ថុ........................................ ១០ ២០៥ ៦២៧,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន......................... ១១ ០៣០ ៤៦០,៩ លានរៀល

ដូច្នេះ ចំណូលអនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន......៨២៤ ៨៣៣,៩ លានរៀល ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ :

១. ចំណូលចរន្ត
- ច្បាប់ហិរញ្ញវត្ថុ..............................................៩ ៧១២ ៦២៧,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន..........................១០ ៨២៩ ៦៩៦,៦ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន.........................១ ១១៧ ០៦៩,៦ លានរៀល ។

២. ចំណូលមូលធន
- ច្បាប់ហិរញ្ញវត្ថុ..............................................៤៩៣ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន................................២០០ ៧៦៤,៣ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ២៩២ ២៣៥,៧ លានរៀល ។

ក. ចំណូលមូលធនក្នុងប្រទេស

- ច្បាប់ហិរញ្ញវត្ថុ........................................ ២៣៣ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.............................. ១៨៣ ៩៩៦,១ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន............................. ៤៩ ០០៣,៩ លានរៀល ។

ខ. ចំណូលមូលធនក្រៅប្រទេស(មូលនិធិទ្រទ្រង់ថវិកា)

- ច្បាប់ហិរញ្ញវត្ថុ.........................................២៦០ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន................................. ១៦ ៧៦៨,២ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន..........................២៤៣ ២៣១,៨ លានរៀល ។

## មាត្រា ៤.–

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ សម្រេចបានលទ្ធផលដូចតទៅ:

- ច្បាប់ហិរញ្ញវត្ថុ..........................................១០ ១៣៥ ៦២៧,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.............................. ៩ ៨២៧ ៤៥២,១ លានរៀល

ដូច្នេះ ចំណាយអនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន...៣០៨ ១៧៤,៩ លានរៀល ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ :

១. ចំណាយចរន្ត

- ច្បាប់ហិរញ្ញវត្ថុ........................................... ៨ ២៦៨ ៧០៣,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.............................. ៨ ២០៤ ៤៤១,៧ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.............................. ៦៤ ២៦១,៣ លានរៀល ។

២. ចំណាយមូលធន

- ច្បាប់ហិរញ្ញវត្ថុ........................................... ១ ៨៦៦ ៩២៤,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន................................ ១ ៦២៣ ០១០,៤ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន............................ ២៤៣ ៩១៣,៦ លានរៀល ។

ក. ចំណាយមូលធន សម្រាប់វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ច្បាប់ហិរញ្ញវត្ថុ...................................... ១ ៥៣៦ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ១ ៣១១ ២៣១,៥ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន........................ ២២៤ ៧៦៨,៥ លានរៀល។

ខ. ចំណាយមូលធន សម្រាប់ការរំលស់បំណុល

- ច្បាប់ហិរញ្ញវត្ថុ.......................................៣៣០ ៩២៤,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន............................ ៣១១ ៧៧៨,៩ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន............................ ១៩ ១៤៥,១ លានរៀល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង